ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១៩៦ MOC / M 2004

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារ សំរាប់សហគ្រាសធុនតូច និងមធ្យម

******

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងសេចក្តីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មាការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារប្រចាំក្រសួងពាណិជ្ជកម្ម សំរាប់ធ្វើការជាមួយអនុគណៈកម្មាការ សហគ្រាសធុនតូច និងមធ្យម ក្នុងគោលដៅធ្វើឱ្យមានការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យមនៅព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- លោក **ហួរ សាវ៉ាន់** | ប្រធាននាយកដ្ឋាននីតិកម្ម | អនុប្រធាន |
| ៣- លោក **ជួន ចន** | ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | សមាជិក |
| ៤- លោក **អ៊ុន ប៊ុនថា** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |
| ៥- លោក **សុខ សុគន្ធ** | មន្ត្រីនាយកដ្ឋាននីតិកម្ម | សមាជិក |
| ៦- កញ្ញា **នួន ផានិត** | មន្ត្រីនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821688 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

**ប្រការ** ២ : ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម:

- បំពេញការងារតាមការណែនាំ និងតាមទិសដៅ របស់អនុគណៈកម្មការសហគ្រាសធុនតូច និងមធ្យម។
- លើកគម្រោងការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ដែលទាក់ទងដល់ការអភិវឌ្ឍន៍ សហគ្រាសធុនតូច និងមធ្យម ។
- ផ្តល់អនុសាសន៍ ដល់អនុគណៈកម្មការ លើបញ្ហាអភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម។
- សំរបសំរួលការងារជាមួយក្រុមការងាររបស់ក្រសួងនានា ។

**ប្រការ** ៣ : នាយិកាខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ នឹងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

**ចម្លងជូន:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-ប្រធានអនុគណៈកម្មការសហគ្រាសធុនតូច-មធ្យម

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ